# របៀបរាយការណ៍ពីការរើសអើងជាតិសាសន៍ និងការរើសអើងនៅសាលារៀនរបស់កូនអ្នក



Khmer

**កូនរបស់អ្នកសមនឹងទទួលបានការគោរព ឱ្យតម្លៃ និងគោរពស្មើភាពគ្នានៅក្នុងសហគមន៍សាលារៀន។**

**ការរើសអើង ឬការរំលោភបំពានដោយផ្អែកលើសាសនា ឬពូជសាសន៍ មិនត្រូវបានអត់ឱនឡើយ។**

ប្រសិនបើអ្នកជាឪពុកម្តាយ ឬជាអ្នកថែទាំកុមារដែលបានជួបប្រទះ ឬបានឃើញការរើសអើងសាសនា ឬពូជសាសន៍ ឬការរំលោភបំពាននៅសាលារៀនរបស់ពួកគេ យើងលើកទឹកចិត្តឱ្យអ្នករាយការណ៍អំពីរឿងនេះ។

បុគ្គលិកសាលាអាចប្រាកដថាសកម្មភាព និងជំនួយសមរម្យត្រូវបានផ្តល់ជូន។

អ្នកអាចចង់ធ្វើបណ្តឹងតវ៉ាជាផ្លូវការអំពីឧប្បត្តិហេតុនេះទៅសាលារៀន ឬការិយាល័យប្រចាំតំបន់។

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ៖
លើកបណ្តឹងតវ៉ា ឬកង្វល់អំពីសាលារៀនរបស់អ្នក (education.vic.gov.au)

## រាយការណ៍ពីឧប្បត្តិហេតុនៅលើ បណ្តាញទូរសព្ទទាន់ហេតុការណ៍ដើម្បីរាយការណ៍អំពីការរើសអើងពូជសាសន៍ (REPORT RACISM HOTLINE)

**Report Racism Hotline**

1800 722 476

report.racism@education.vic.gov.au

បណ្តាញទូរសព្ទទាន់ហេតុការណ៍ ដំណើរការចាប់ពីម៉ោង 9 ព្រឹក ដល់ម៉ោង 5 ល្ងាច ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ដោយមិនរាប់បញ្ចូលថ្ងៃបុណ្យសាធារណៈ។

ប្រសិនបើអ្នកមិនមានអារម្មណ៍សុខស្រួលក្នុងការរាយការណ៍អំពីឧប្បត្តិហេតុមួយទៅកាន់សាលារៀនរបស់កូនអ្នកទេ ឬប្រសិនបើអ្នកមិនសប្បាយចិត្តនឹងការឆ្លើយតបរបស់សាលារៀន អ្នកអាចទាក់ទង Report Racism Hotline របស់ក្រសួង។

នៅពេលអ្នកហៅទូរសព្ទទៅបណ្តាញទូរសព្ទទាន់ហេតុការណ៍ អ្នកនឹងអាច៖

- ពិភាក្សាអំពីការធ្វើបណ្តឹងតវ៉ា
- ពិចារណាអំពីជម្រើសនានាដែលមាន និងអ្វីដែលអ្នកអាចធ្វើបានបន្ទាប់
- ទទួលបានជំនួយក្នុងការទាក់ទងមន្ត្រីប្រចាំតំបន់ និងសេវាកម្មគាំទ្រនានា។

## ទទួលបានការប្រឹក្សាតាមទូរសព្ទ និងជំនួយតាមរយៈ PARENTLINE

**Parentline**

13 22 89

www.parentline.vic.gov.au

Parentline ដំណើរការចាប់ពីម៉ោង 8 ព្រឹក ដល់ពាក់កណ្តាលអធ្រាត្រ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងថ្ងៃបុណ្យសាធារណៈ។

អ្នកក៏អាចចង់ទាក់ទងមក Parentline ផងដែរ ដើម្បីស្វែងរកការប្រឹក្សា និងការគាំទ្រពីអ្នកប្រឹក្សាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលឯករាជ្យពីក្រសួង។

Parentline គឺជាសេវាកម្មទូរសព្ទប្រឹក្សាសម្ងាត់ និងអនាមិក សម្រាប់ឪពុកម្តាយ និងអ្នកថែទាំកុមារចាប់ពីកំណើត ដល់អាយុ 18 ឆ្នាំ។

អ្នកប្រឹក្សាអាចរកបានដើម្បីនិយាយអំពីបញ្ហាចិញ្ចឹមកូនជាច្រើន រួមទាំងការរើសអើង ឬការរំលោភបំពាននៅសាលារៀន។

## ព័ត៌មានដែលមានប្រយោជន៍

សម្រាប់ព័ត៌មានបន្ថែមស្តីពីការរាយការណ៍អំពីការរើសអើងជាតិសាសន៍ និងការរំលោភបំពាននៅសាលារៀន សូមមើលគេហទំព័រ៖
រាយការណ៍ពីការរើសអើងជាតិសាសន៍ ឬការរើសអើងសាសនានៅសាលារៀន (education.vic.gov.au)

សម្រាប់ព័ត៌មានបន្ថែម និងធនធានអំពីការឆ្លើយតបទៅនឹងការសម្លុតធ្វើបាប រួមទាំងការរើសអើងជាតិសាសន៍ សូមមើលគេហទំព័រ៖
អ្នកបញ្ឈប់ការសម្លុតធ្វើបាប (education.vic.gov.au)

### សេវាកម្មជាតិបកប្រែភាសាសរសេរ និងផ្ទាល់មាត់ (TIS)

មាតាបិតា ឬអ្នកថែទាំដែលត្រូវការសេវាកម្មបកប្រែផ្ទាល់មាត់ អាចទាក់ទងក្រសួង ឬ Parentline ដោយទូរសព្ទទៅសេវាកម្មជាតិបកប្រែភាសាសរសេរ និងផ្ទាល់មាត់ (TIS) តាមលេខ 13 14 50។